**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

www.pheakdeylaw.com

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្របតាមមាត្រា៩៧នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់មូលនិធិខាងលើនេះ ឲ្យមាននិរន្តរភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សកម្មភាពសម្ងាត់ និងបន្ទាន់ សំដៅរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនប្រកបដោយប្រសិទ្ធភាព។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើសកម្មភាពទាក់ទងនឹងការប្រមូល ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់មូលនិធិដែលជាផលបានមកពីការរឹបអូសពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

## ជំពូកទី២
## ការគ្រប់គ្រងនិងការត្រួតពិនិត្យមូលនិធិ

**មាត្រា៤ .-**

មូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវគ្រប់គ្រង ត្រួតពិនិត្យ និងចាត់ចែងដោយប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**មាត្រា៥ .-**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាសេនាធិការរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការគ្រប់គ្រងនិងការចាត់ចែងបេឡាមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងនិងចាត់ចែងមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមការចង្អុលបង្ហាញរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- តាមដាននិងត្រួតពិនិត្យអំពីប្រភពចំណូលនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- លើកសំណើការប្រើប្រាស់មូលនិធិ ជូនប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនពិនិត្យនិងសម្រេច។

**មាត្រា៦ .-**

បេឡាមូលនិធិរបស់អាជ្ញាធរជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវតម្កល់ទុកក្នុងគណនីមួយរបស់រតនាគារជាតិឬធនាគារពាណិជ្ជជាដៃគូណាមួយ តាមការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



www.pheakdeylaw.com

## ជំពូកទី៣
## ភ្នាក់ងារគណនេយ្យនិងបែបបទចំណូល ចំណាយ

**មាត្រា៧ .-**

មូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវមានភ្នាក់ងារគណនេយ្យមួយរូបដែលតែងតាំងដោយប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ភ្នាក់ងារគណនេយ្យមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវលើការទទួលចំណូលនិងរាល់ប្រតិបត្តិការចំណាយរបស់មូលនិធិ
- ចុះទិដ្ឋាការនិងទូទាត់ចំណាយទាំងឡាយនៃមូលនិធិ ដោយមានការឯកភាពពីប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអនុលោមតាមវិធាននិងបទប្បញ្ញត្តិពាក់ព័ន្ធការទូទាត់ចំណាយថវិការដ្ឋ
- ធ្វើរបាយការណ៍ពីស្ថានភាពចំណូល ចំណាយជាក់ស្តែងសម្រាប់ខែនីមួយៗ ដាក់ជូនប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងចម្លងជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រក្សាទុកលិខិតយុត្តិកម្មនៃកិច្ចប្រតិបត្តិការនីមួយៗនិងឯកសារគណនេយ្យដែលពាក់ព័ន្ធ
- គ្រប់គ្រងនិងថែរក្សារាល់ទ្រព្យសម្បត្តិមានតម្លៃនិងវត្ថុផ្សេងទៀត រួមទាំងឯកសារពាក់ព័ន្ធ ដែលបានដាក់ចូលក្នុងមូលនិធិ។

## ជំពូកទី៤
## ការប្រើប្រាស់មូលនិធិ

**មាត្រា៨ .-**

មូលនិធិរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវប្រើប្រាស់ក្នុងមុខសញ្ញាចំណាយដូចខាងក្រោម៖

- ទូទាត់បំណុលនិងរាល់ចំណាយស្របច្បាប់ដែលកើតឡើងពីការរឹបអូសជាសាច់ប្រាក់ ទ្រព្យសម្បត្តិ និងផលផ្សេងៗ ដែលបានពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលរាប់បញ្ចូលទាំងការចំណាយលើការរឹបអូស ការដឹកជញ្ជូន ការទុកដាក់ និងការថែរក្សា
- សងសំណងដល់ជនរងគ្រោះ ប្រសិនបើមាន
- ផ្តល់ឲ្យអង្គការរដ្ឋឬឲ្យទៅសមាគមឯកជន ក្នុងគោលបំណងគាំទ្រការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់ឬការប្រព្រឹត្តបទល្មើសពាក់ព័ន្ធគ្រឿងញៀន
- ធ្វើវិភាគទានដល់ស្ថាប័ន អង្គភាព ឬអង្គការឯកទេសនានា ដែលធ្វើសកម្មភាពក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសគ្រឿងញៀន ការស្រាវជ្រាវវិទ្យាសាស្ត្រ ការធ្វើពិសោធន៍គ្រឿងញៀន ការព្យាបាល និងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- ផ្តល់ការលើកទឹកចិត្តដល់មន្ត្រីភ្នាក់ងារឬអង្គភាពដែលមានស្នាដៃឆ្នើមក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ព្រមទាំងមន្ត្រីដែលបំពេញភារកិច្ចក្នុងការគ្រប់គ្រងនិងប្រមូលចំណូលដែលបានមកពីបទល្មើសគ្រឿងញៀន។

នីតិវិធីលម្អិតសម្រាប់ការប្រើប្រាស់មូលនិធិខាងលើ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។/.



www.pheakdeylaw.com

**មាត្រា៩ .-**

ក្រសួង ស្ថាប័ន អង្គភាព ឬអង្គការឯកទេសនានាដែលមានបំណងទទួលមូលនិធិរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវដាក់ពាក្យសុំមកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយភ្ជាប់មកជាមួយនូវព័ត៌មានលម្អិត ដែលកំណត់ដោយអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ក្នុងករណីសំណើវិភាគទានត្រូវបានអនុញ្ញាត អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវថតចម្លងឯកសារមួយច្បាប់ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## ការតាមដានការប្រមូលមូលនិធិ

**មាត្រា១០ .-**

មន្ត្រីនគរបាលយុត្តិធម៌ ដែលដឹកនាំកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ត្រូវផ្ញើបញ្ជីមកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាល់មុខសញ្ញាដែលជាប្រភពនៃមូលនិធិពាក់ព័ន្ធបទល្មើសគ្រឿងញៀន។

**មាត្រា១១ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបង្កើតយន្តការអន្តរក្រសួង ស្ថាប័នមួយ ដើម្បីប្រមូល គ្រប់គ្រង និងចាត់ចែងមូលនិធិដូចមានចែងនៅក្នុងមាត្រាខាងលើនេះ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនឬតំណាងស្របច្បាប់ ត្រូវចូលរួមនៅក្នុងដំណើរការយន្តការនេះ ដើម្បីធានាថាការប្រមូល ការគ្រប់គ្រង និងការចាត់ចែងមូលនិធិខាងលើនេះ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

យន្តការខាងលើនេះត្រូវបង្កើតឡើងដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

## ជំពូកទី៦
## ប្រភពចំណូលនៃមូលនិធិ

**មាត្រា១២ .-**

មូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀនទទួលបានមកពី៖

- ថវិការដ្ឋដែលផ្តល់ឲ្យតាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានប្រភពមកពីទ្រព្យសម្បត្តិជាសាច់ប្រាក់ដែលត្រូវបានរឹបអូសពីបទល្មើសគ្រឿងញៀន រួមទាំងផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសគ្រឿងញៀន និងប្រាក់ដែលបានមកពីការលក់វត្ថុ ការចាត់ចែង ឬទ្រព្យសម្បត្តិដែលត្រូវបានរឹបអូស ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- អំណោយឬជំនួយថវិកា សម្ភារៈ ឧបករណ៍នានាពីសប្បុរសជន ស្ថាប័នជាតិនិងអន្តរជាតិនានាដែលជាប្រភពស្របច្បាប់។/.

www.pheakdeylaw.com

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ មីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**កែ គឹមយ៉ាន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com